# លទ្ធផលសង្ខេបនៃកិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធអំពី
# របាយការណ៍ពាក់កណ្ដាលអាណត្តិនៃការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកល
# តាមកាលកំណត់ (យូ.ភី.អ)
# អំពី សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅក្នុងប្រទេសកម្ពុជា

ខែមីនា-មេសា ឆ្នាំ២០២២

ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# សេចក្តីផ្តើម

## អង្គការសង្គមស៊ីវិលចូលរួមរៀបចំ និងគាំទ្ររបាយការណ៍ពាក់កណ្តាលអាណត្តិ នៃការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (យូ.ភី.អ) ជុំទី៣ អំពី សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅក្នុងប្រទេសកម្ពុជា

ខ្ញុំទទួលយក

RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# កាលបរិច្ឆេទ៖ អង្គការសង្គមស៊ីវិលចូលរួមនៅក្នុងដំណើរការយន្តការ យូ.ភី.អ ជុំទី៣ ស្តីពី សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅក្នុងប្រទេសកម្ពុជា (SOGIESC-SRHR)

១

- ឆ្នាំ២០១៩៖ ការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ជុំទី៣នៅប្រទេសកម្ពុជា (យូ.ភី.អ) ➔ ប្រទេសកម្ពុជាបានទទួលយកអនុសាសន៍អំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ
- **ខែឧសភា ឆ្នាំ២០១៩៖** កិច្ចសន្ទនាស្តីពីច្បាប់ និងគោលនយោបាយគាំពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា

ខ្ញុំទទួលយក

RCK RAINBOW COMMUNITY KAMPUCHEA ORGANISATION

២

- **២០១៨៖** ពិភាក្សាជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ( LGBT+ ) ក្នុងការកំណត់បញ្ហាអាទិភាពនៅក្នុងការរៀបចំរបាយការណ៍ យូ.ភី.អ អំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ
- **ខែកក្កដា ឆ្នាំ២០១៨៖** ការផ្សព្វផ្សាយរបាយការណ៍ យូ.ភី.អ របស់សង្គមស៊ីវិលអំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅកម្ពុជា
- **ខែសីហា ឆ្នាំ២០១៨ - ខែមករា ឆ្នាំ២០១៩៖ ការតស៊ូមតិជាមួយភាគីពាក់ព័ន្ធទាក់ទងនឹងការពិនិត្យលើរបាយការណ៍ យូ.ភី.អ**

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

៣

- **ខែកញ្ញា ឆ្នាំ២០២១៖ សេចក្តីថ្លែងការណ៍របស់អង្គការសង្គមស៊ីវិលចំនួន១៦ ស្តីពី** *"ការបង្កើនកិច្ចខំប្រឹងប្រែងបន្ថែមទៀតក្នុងការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា (LGBT+) នៅក្នុងប្រទេសកម្ពុជា ដើម្បីឆ្លើយតបនឹងអនុសាសន៍នៃការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់(យូ.ភី.អ) ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក"*
  - ➢ កិច្ចសន្ទនាជាមួយតំណាងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋដែលបានផ្តល់អនុសាសន៍ យូ.ភី.អ និងភ្នាក់ងារអង្គការសហប្រជាជាតិ។

៤

- **ខែធ្នូ ឆ្នាំ២០២១៖** កិច្ចសន្ទនាតុមូលស្តីពីការបង្កើនកិច្ចការពារផ្នែកច្បាប់ដល់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា
- **ខែធ្នូ ឆ្នាំ២០២១៖** សម្ពោធយុទ្ធនាការ "**ខ្ញុំទទួលយក**" ដើម្បីគាំទ្រវឌ្ឍនភាពនៃការប្តេជ្ញាចិត្តអនុវត្តអនុសាសន៍ យូ.ភី.អ ជុំទី៣ ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយកអំពីការការពារផ្លូវច្បាប់សម្រាប់សមភាពអាពាហ៍ពិពាហ៍ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION

៥

- **ខែមីនា ឆ្នាំ២០២២៖ ផ្សព្វផ្សាយរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (យូ.ភី.អ) របស់បណ្តាញអង្គការសង្គមស៊ីវិល** ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ នៅប្រទេសកម្ពុជា
  - កិច្ចសន្ទនាជាមួយតំណាងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋដែលបានផ្តល់អនុសាសន៍ យូ.ភី.អ និងទីភ្នាក់ងារអង្គការសហប្រជាជាតិ។

នៅក្នុងជំណាក់កាលពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ជុំទី៣ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានទទួលយកអនុសាសន៍ចំនួន៩ អំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិបន្តពូជ

| Recommendations on SOGIESC rights accepted by Cambodia during its third UPR | |
|---|---|
| **Recommendations** | **Recommending State** |
| **Amend the Constitution to enable legal marriage equality for same-sex couples** | |
| Amend the Constitution to ensure marriage equality for same-sex couples. (110.47) | Iceland |
| Amend article 45 of the Constitution so as to enable legal marriage equality with a view to pursuing full and equal treatment of lesbian, gay, bisexual, transgender and intersex persons in all areas. (110.51) | Netherlands |
| Amend article 45 of the Constitution to allow same-sex couples to marry. (110.55) | Canada |
| **Enactment of laws and policies guaranteeing non-discrimination on the basis of SOGIESC** | |
| Introduce an anti-discrimination law that guarantees and explicitly prohibits all kinds of discrimination, including on the basis of sexual orientation, gender identity or sex characteristics. (110.45) | Iceland |
| Adopt, in consultation with civil society organizations, comprehensive legislation and policies against discrimination and violence based on sexual orientation or gender identity, and guarantee their implementation through all public entities, in particular in the education, health and labor sectors. (110.50) | Mexico |
| Introduce new legislation that guarantees equality and explicitly prohibits discrimination against lesbian, gay, bisexual, transgender and intersex persons. (110.52) | Sweden |
| Adopt effective measures to combat and punish discrimination and violence motivated by sexual orientation or gender identity. (110.53) | Uruguay |
| Introduce, by the end of 2023, an anti-discrimination law that guarantees equality and explicitly prohibits discrimination of all kinds, including on the basis of religion, sexual orientation, gender identity and expression or sex characteristics. (110.54) | Australia |
| **Enact legislation to enable legal gender recognition for trans people** | |
| Introduce a gender recognition law. (110.54) | Iceland |

RAINBOW COMMUNITY KAMPUCHEA ORGANISATION

# របាយការណ៍ពាក់កណ្តាលអាណត្តិ យូ.ភី.អ ជុំទី៣ របស់អង្គការសង្គមស៊ីវិលស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជនៅកម្ពុជា

ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២

- ចូលរួមរៀបចំគាំទ្រដោយអង្គការសង្គមស៊ីវិលចំនួន១៩

**Sexual Orientation, Gender Identity and Expression and Sex Characteristics (SOGIESC) Rights and Sexual Reproductive Health and Rights (SRHR) in Cambodia**

**Universal Periodic Review (UPR) Mid-term report for the third UPR of the Kingdom of Cambodia**

*03 March 2022*

*Joint-report prepared by Rainbow Community Kampuchea Organization ("RoCK"), the Cambodian Center for Human Rights ("CCHR"), the Reproductive Health Association of Cambodia ("RHAC"), Micro Rainbow International Foundation("MRIF"), and also endorsed by Gender and Development for Cambodia ("GADC"), Klahaan Organization, SILAKA Cambodia, ActionAid Cambodia, DanChurchAid Cambodia ("DCA"), Save the Children, ILGA Asia, APCOM, Asia Pacific Alliance for Sexual and Reproductive Health and Rights ("APA") , Asian Pacific Resource and Research Centre for Women ("ARROW"), Just Associates Southeast Asia ("JASS SEA"), ILGA World – the International Lesbian, Gay, Bisexual, Trans and Intersex Association, the Swedish Association for Sexuality Education ("RFSU"), International Women's Development Agency ("IWDA"), Destination Justice.*

- បង្ហាញពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍យូ.ភី.អ ស្តីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ ដែលកម្ពុជាបានទទួលយក នៅឆ្នាំ២០១៩
- ស្នើអនុសាសន៍ជូនដល់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធនៃរបាយការណ៍ យូ.ភី.អ រួមបញ្ចូលទាំងរដ្ឋដែលបានផ្តល់អនុសាសន៍ និងភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីដោះស្រាយភាពចន្លោះប្រហោងនៃការអនុវត្ត និងធ្វើឱ្យប្រាកដនូវការអនុវត្តអនុសាសន៍ ដែលកម្ពុជាបានទទួលយកស្តីពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ ឱ្យបានមុន យូ.ភី.អ ជុំបន្ទាប់ ដើម្បីការពារសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេសកម្ពុជា។

*សូមអានរបាយការណ៍ពាក់កណ្តាលអាណត្តិទាំងស្រុង៖*

https://rockcambodia.org/universal-periodic-review-upr-mid-term-report-on-the-rights-of-lesbian-gay-bisexual-transgender-lgbt-people-in-cambodia/

# សន្លឹកព័ត៌មានសង្ខេបនៃរបាយការណ៍ យូ.ភី.អ ពាក់កណ្ដាលអាណត្តិរបស់អង្គការសង្គមស៊ីវិល

ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា

RUCK

RAINBOW COMMUNITY KAMPUCHEA ORGANISATION

**កិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធអំពីរបាយការណ៍ពិនិត្យស្ថានភាពសិទ្ធិមនុស្ស ជាសកលតាមកាលកំណត់ ( យូ.ភី.អ ) ពាក់កណ្តាលអាណត្តិ**

**អំពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅក្នុងប្រទេសកម្ពុជា**

**ខែមីនា - មេសា ឆ្នាំ២០២២**

RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# កិច្ចសន្ទនាជាមួយភាគីពាក់ព័ន្ធអំពីរបាយការណ៍ពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ពាក់កណ្ដាលអាណត្តិស្ដីពី សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជនៅកម្ពុជា

**ចាប់ពីខែមីនា ដល់ខែមេសា ឆ្នាំ ២០២២** បន្ទាប់ពីការបោះពុម្ពផ្សាយរបាយការណ៍ពាក់កណ្ដាលអាណត្តិរបស់អង្គការសង្គមស៊ីវិលស្ដីពីសិទ្ធិ សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងសិទ្ធិសុខភាពផ្លូវភេទនិងបន្តពូជ សហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់) រួមជាមួយនិងក្រុមក្ដីស្រឡាញ់គឺចម្រុះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អង្គការថែទាំសុខភាពគ្រួសារកម្ពុជា(រ៉ាក់) និងមូលនិធិមីក្រូឥន្ទធនូអន្តរជាតិកម្ពុជា បានរៀបចំកិច្ចប្រជុំជាបន្តបន្ទាប់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដូចជា៖

- **តំណាងមកពីរាជរដ្ឋាភិបាលកម្ពុជា រួមទាំងគណៈកម្មាធិការសិទ្ធិមនុស្ស ក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃ។**
- តំណាងពីរដ្ឋដែលផ្តល់អនុសាសន៍ ដូចជា កាណាដា ហូឡង់ អ៊ីស្លង់ អូស្ត្រាលី ស៊ុយអ៊ែត និង ម៉ិចស៊ីកូ តាមរយៈស្ថានទូត និងការិយាល័យស្ថានទូត។
- តំណាងមកពីភ្នាក់ងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ដូចជា ការិយាល័យអ្នកសម្របសម្រួល ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស UNFPA និងUNICEF។
- ក៏បានចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការត្រួតពិនិត្យជាសកលតាមកាលកំណត់ ( យូ.ភី.អ ) របស់រាជរដ្ឋាភិបាល ដែលបានរៀបចំដោយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។

គោលបំណងនៃកិច្ចសន្ទនា៖

- ពិភាក្សាពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ យូ.ភី.អ ជុំទី៣ ពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលយក នៅឆ្នាំ២០១៩។
- ពិភាក្សាអំពីវឌ្ឍនភាពសម្រាប់ការគាំទ្រការការពារសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាដោយស្មើភាពគ្នាស្របតាមការគាំទ្រការអនុវត្តអនុសាសន៍ យូ.ភី.អ និងឆ្ពោះទៅរកការធ្វើឱ្យសមភាពច្បាប់អាពាហ៍ពិពាហ៍ដៃគូអ្នកស្រឡាញ់ភេទដូចគ្នា ដែលជាតម្រូវការអាទិភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

# រាជរដ្ឋាភិបាលកម្ពុជា

កិច្ចពិភាក្សាតាមប្រព័ន្ធអនឡាញ ជាមួយតំណាងរាជរដ្ឋាភិបាលរួមមាន៖

- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- ក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមនៃក្រសួងកិច្ចការនារី
- *បណ្តាញសហគមន៍យើងក៏នឹងគ្រោងស្នើជួបពិភាក្សាជាមួយក្រសួងយុត្តិធម៌នៅពេលក្រោយផងដែរ។*

*ចំណុចសំខាន់ត្រូវបានពិភាក្សា ៖*

*➔ ស្នើសុំបង្កើតក្រុមការងារដែលមានសមាសភាពចម្រុះ ដើម្បីទទួលបន្ទុកសិក្សា និងត្រួតពិនិត្យការស្នើវិសោធនកម្មច្បាប់ ដើម្បីអនុញ្ញាតឱ្យមានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា ដែលស្ថិតក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។*







ខ្ញុំទទួលយក

RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# តំណាងស្ថានទូតនៃរដ្ឋដែលផ្តល់អនុសាសន៍

ជួបជាមួយតំណាងរដ្ឋដែលបានផ្តល់អនុសាសន៍យូ.ភី.អ រួមមាន៖

- ការិយាល័យស្ថាតទូត**កាណាដា**ប្រចាំកម្ពុជា
- ស្ថាតទូត**អ៊ីស្លង់** ប្រចាំនៅទីក្រុងប៉េកាំង
- ស្ថានទូតនៃ**ព្រះរាជាណាចក្រហូឡង់**ប្រចាំប្រទេសថៃ
- ស្ថានទូត**ម៉ិចស៊ីកូ**ប្រចាំប្រទេសថៃ
- ស្ថានទូត**អូស្ត្រាលី**ប្រចាំប្រទេសកម្ពុជា
- ការិយាល័យនៃស្ថានទូត**ស៊ុយអែត** នៅទីក្រុងភ្នំពេញ















*ចំណុចសំខាន់ត្រូវបានពិភាក្សា ៖*

*➔ សំណើសុំឱ្យរដ្ឋផ្តល់អនុសាសន៍គាំទ្រការអនុវត្តអនុសាសន៍ យូ.ភី.អ លើសិទ្ធិ SOGIESC-SRHR រួមទាំងការបន្តកិច្ចសន្ទនាលើការការពារសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ដោយពិចារណាផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងចែករំលែកបទពិសោធន៍ក្នុងការអនុម័តច្បាប់សមភាពអាពាហ៍ពិពាហ៍។*

# ភ្នាក់ងារអង្គការសហប្រជាជាតិ

*«ក្នុងអំឡុងពេលនៃការសន្ទនារបស់ខ្ញុំជាមួយសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា ពួកគេបានកំណត់ជាអាទិភាពនូវការទទួលបានសមភាពច្បាប់អាពាហ៍ពិពាហ៍ ដើម្បីការពារសិទ្ធិរបស់ពួកគេ និងកាត់បន្ថយការរើសអើងដែលពួកគេកំពុងប្រឈមមុខ។ អង្គការសហប្រជាជាតិបានគាំទ្រអនុសាសន៍របស់ប្រទេសអ៊ីស្លង់ ហូឡង់ និងកាណាដាក្នុងការអនុញ្ញាតឱ្យដៃគូភេទដូចគ្នាអាចរៀបការ ដើម្បីលើកកម្ពស់ភាពស្មើគ្នាសម្រាប់ប្រជាជនទាំងអស់ ។»*




សុន្ទរកថារបស់លោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើរបាយការណ៍ពាក់កណ្តាលអាណត្តិ យូ.ភី.អ ជុំទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលរៀបចំដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និង OHCHR នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២។



ខ្ញុំទទួលយក

RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION







# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើរបាយការណ៍ពាក់កណ្ដាលអាណត្តិនៃការត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់

ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

ទន្ទឹមនឹងមានវឌ្ឍនភាពមួយចំនួន ប៉ុន្តែសង្គមស៊ីវិល តាមរយៈការចូលរួមរបស់សហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) **បានស្នើដល់រាជរដ្ឋាភិបាលឱ្យមានកិច្ចខិតខំប្រឹងប្រែង និងរៀបចំសកម្មភាពជាក់លាក់បន្ថែមទៀតក្នុងការវិសោធនកម្មច្បាប់ដើម្បីអនុញ្ញាតឱ្យដៃគូភេទដូចគ្នាអាចរៀបការបាន។**

ឯកឧត្តម កត្តា អ៊ន សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបានស្វាគមន៍ចំពោះកិច្ចសហការរវាងអង្គការសង្គមស៊ីវិល និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីដោះស្រាយបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា ហើយបានអំពាវនាវដល់រ៉ក់ធ្វើការចងក្រងច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ភេទដូចគ្នា របស់ប្រទេសដទៃ ដើម្បីឲ្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាប្រើប្រាស់ជាមូលដ្ឋានគ្រឹះសម្រាប់ការសិក្សា និងតស៊ូមតិបន្តទៀត។

# ជំហានបន្ទាប់

ខ្ញុំទទួលយក

RUCK
RAINBOW COMMUNITY KAMPUCHEA
ORGANISATION

# ក្នុងរយៈពេល ២ ឆ្នាំខាងមុខ មុនដល់ យូ.ភី.អ ជុំទី ៤ របស់កម្ពុជា ដែលបានគ្រោងទុកនៅឆ្នាំ ២០២៤៖

- បន្តកិច្ចសន្ទនាជាប្រចាំ និងយ៉ាងសកម្មជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីជំរុញឱ្យមានការការពារស្មើភាពគ្នា នៃសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា ស្របតាមការគាំទ្រការអនុវត្តអនុសាសន៍ UPR និងឆ្ពោះទៅរកការធ្វើឱ្យមានសមភាពអាពាហ៍ពិពាហ៍ដៃគូអ្នកស្រឡាញ់ភេទដូចគ្នាដែលជាតម្រូវការអាទិភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា។

- រៀបចំដំហានដាក់លាក់ក្នុងការធ្វើការរួមគ្នាជាមួយអ្នកពាក់ព័ន្ធ ដើម្បីបង្កើតក្រុមការងារដែលមានសមាសភាពចម្រុះ ទទួលបន្ទុកសិក្សា និងត្រួតពិនិត្យការស្នើវិសោធនកម្មច្បាប់ពាក់ព័ន្ធ ដើម្បីអនុញ្ញាតសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូភេទដូចគ្នា រួមទាំងសិក្សាពីបទពិសោធន៍របស់ប្រទេសដទៃក្នុងការធ្វើច្បាប់សមភាពអាពាហ៍ពិពាហ៍។

- យុទ្ធនាការ «ខ្ញុំទទួលយក» បង្កើតឡើងដើម្បីគាំទ្រនូវវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍ យូ.ភី.អ ។ យុទ្ធនាការនេះនឹងលើកយកសំឡេង និងរឿងរ៉ាវរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា រួមទាំងក្រុមគ្រួសារ ឪពុកម្តាយ អ្នកគាំទ្រនៅគ្រប់វិស័យ និងសាធារណជននៅទូទាំងប្រទេសតាមរយៈសារព័ត៌មាន និងបណ្តាញព័ត៌មានសង្គម ដើម្បីទទួលបានការយល់ដឹង ការទទួលស្គាល់ និងការគាំទ្របន្ថែមទៀតចំពោះសារៈសំខាន់នៃការទទួលបានសមភាពច្បាប់អាពាហ៍ពិពាហ៍សម្រាប់ដៃគូអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។

# ការចេញផ្សាយអត្ថបទព័ត៌មាន

- របាយការណ៍ពាក់កណ្ដាលអាណត្តិរបស់អង្គការសង្គមស៊ីវិល ស្ដីពីសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ នៅខែមីនា ឆ្នាំ២០២២
- កិច្ចសន្ទនាថ្នាក់ជាតិ និងការសម្ពោធយុទ្ធនាការសមភាពអាពាហ៍ពិពាហ៍ "ខ្ញុំទទួលយក" នៅខែធ្នូ ឆ្នាំ ២០២១
- សេចក្ដីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិលក្នុងឱកាសនៃរបាយការណ៍ពិនិត្យស្ថានភាពសិទ្ធិមនុស្សជាសកលតាមកាលកំណត់ (យូ.ភី.អ) ពាក់កណ្ដាលអាណត្តិ អំពី សិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ និងសិទ្ធិសុខភាពផ្លូវភេទ និងបន្តពូជ ក្នុងខែកញ្ញា ឆ្នាំ ២០២១

ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# ការចេញផ្សាយអត្ថបទព័ត៌មាន

- *RFI,* កញ្ញា លី ពិសី៖ អាពាហ៍ពិពាហ៍ស្របច្បាប់សំខាន់ក្នុងការបង្ការភាពងាយរងគ្រោះរបស់អ្នកស្រឡាញ់ភេទដូចគ្នា, 03 March 2022. https://fb.watch/cqDHM8_W3n/
- *BTVnews*, សហគមន៍អ្នកស្រលាញ់ភេទដូចគ្នាចង់មានច្បាប់រៀបការ ខណៈប្រធានសិទ្ធិមនុស្សកម្ពុជាគាំទ្រ, 10 December 2021. https://news.btv.com.kh/public/article/7424?fbclid=IwAR3HpLWtXDHh1DBqDKsOez4KNxPu9uQdFREhOhjdir1dmMe7GjBgS1EeHNo https://youtu.be/Lw-E9koZMEs
- *AMS,* យុទ្ធនាការ "ខ្ញុំទទួលយក" បំណងចង់ឱ្យមានសមភាពច្បាប់អាពិពាហ៍ពិពាហ៍អ្នកស្រលាញ់ភេទដូចគ្នា, 10 December 2021. https://ams.com.kh/education/education-update/national/news/i-accept-campaign-wants-equality-in-lgbt-marriage-law/?fbclid=IwAR2p8CWbqRhzZGXZ-POGHxMR0rnEOVTyAAnEzidiV9LFWi0aNkX40IriYGw
- *AMS,* ឯកឧត្តម កែវ រ៉េមី ៖ ខ្ញុំមិនទុកឱ្យអ្នកស្រលាញ់ភេទដូចគ្នារស់នៅឯកានោះទេ, 10 December 2021. https://ams.com.kh/education/life-education/news/he-keo-remy-i-do-not-leave-lgbt-people-alone/
- *Cambodianess,* LGBT+ Community Launches Marriage Campaign, 10 December 2021. https://cambodianess.com/article/lgbt-community-launches-marriage-campaign
- *Freshnews,* មេសិទ្ធិមនុស្សកម្ពុជា ទទួលស្គាល់ថាសង្គមកម្ពុជា មានការរើសអើងការស្រឡាញ់ភេទដូចគ្នា ពីសំណាក់ក្រុមគ្រួសារ សហគម និងមនុស្សនៅជុំវិញខ្លួន,10 December 2021. http://www.freshnewsasia.com/index.php/en/localnews/223090-2021-12-10-04-39-13.html
- *VOD Radios,* ទិវាសិទ្ធិមនុស្សអន្តរជាតិ "ខ្ញុំទទួលយក", 10 December 2021. https://www.facebook.com/VODKhmer/videos/1073090596837202/
- *Thmey Thmey*, យុទ្ធនាការ «ខ្ញុំទទួលយក» ដើម្បីសមភាពច្បាប់រៀបការ ដល់អ្នកស្រឡាញ់ភេទដូចគ្នា, 11 December 2021. https://thmeythmey.com/?page=detail&id=110518&fbclid=IwAR2yIcONpkER7ycAZ5SklE3PMBspihntjCPZnodbyW9lEwOmAb9lCTE0Q9U
- *VOD radio,* ទិវាសិទ្ធិមនុស្សអន្តរជាតិរបស់ស្រឡាញ់ភេទដូចគ្នា ២០២១, 03 December 2021. https://www.facebook.com/VODKhmer/videos/1276945356049979
- *RFI,* អង្គការសមាគមចំនួន១៦ដែលធ្វើការលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូច, 27 Sep 2021. https://m.facebook.com/watch/?v=2067815713356161&_rdr
- *Cambodianess, " LGBTIQ Advocates Urge Same-Sex Marriage Reform" , 30 September 2021.* https://cambodianess.com/article/lgbtiq-advocates-urge-same-sex-marriage-reform?fbclid=IwAR3ftfFV5zkle-AGPkMZV9iT41jhtBUsoSzsXrYLSNm85Fis-ebKi9Fd2hE
- *Khmer Times,* "Sixteen NGOs ask Government to protect LGBTIQ rights", 30 September 2021, https://www.khmertimeskh.com/50944348/sixteen-ngos-ask-government-to-protect-lgbtiq-rights/

ខ្ញុំទទួលយក

RAINBOW COMMUNITY KAMPUCHEA ORGANISATION




ការអនុវត្តអនុសាសន៍ យូ.ភី.អ
ដើម្បីការពារសិទ្ធិអ្នកស្រឡាញ់
ភេទដូចគ្នាក្នុងការរៀបការ
ហើយកាត់បន្ថយការរើសអើង

ខ្ញុំទទួលយក

RUCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION



យើងទាំងអស់គ្នារស់នៅក្នុងសង្គមតែមួយដែលមានសុខដុមរមនាកម្ម។

ខ្ញុំទទួលយក

អង្គការសហគមន៍ឥន្ទធនូកម្ពុជា
RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION